សំរង់ព័ត៌មានប្រចាំសប្តាហ៍

# ស្ថានភាពកុមារនៅកម្ពុជា

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

ឆ្នាំទី១ លេខ ៣ ថ្ងៃទី០៩ ដល់ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៥

មាតិកា ទំព័រ

ទីប្រឹក្សាអគ្គលេខាធិការអ. ស. ប មកពិនិត្យមើលគម្រោងទិសដៅនៃ......១

EAA បានគំរោងជួយចិញ្ចឹមក្មេងកំព្រា....២

បុរសកំរោលមានប្រពន្ធរំលោភ ក្មេងស្រីអាយុ១៥ឆ្នាំ មានផ្ទៃពោះ.......២

អាំប្រុសរំលោភក្មួយស្រីបង្កើត តុលាការសំរេចដាក់គុក១២ឆ្នាំ.........៣

ផឹកស្រាស្រវឹងដេកមិនលក់លួច ចូលក្នុងបន្ទប់ក្មួនក្រមុំគេបំណង.........៤

ឃុំខ្លួនមន្ត្រីយោធាត្រៃទ័ពម្នាក់ ដែលចាប់នារីរំលោភតែពុំបានសំរេច.....៤

សម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែន គាំទ្រក្រសួងកិច្ចការនារីប្រឆាំង.........៥

កុមារគ្រោះដោយសារជំងឺអេដស៍ រកឃើញជំរកមួយនៅវត្តអូពត...........៦

តុលាការផ្តន្ទាទោសអ្នករំលោភក្មេង ស្រីម្នាក់នៅស្រុកស្ទឹងត្រង់..............៧

អំពាវនាវទប់ស្កាត់យុវជនសេព គ្រឿងញៀន.........................៨

## ទីប្រឹក្សាអគ្គលេខាធិការអ.ស.បមកពិនិត្យមើលគម្រោងទិសដៅនៃការអភិវឌ្ឍន៍សហស្សវត្សរ៍នៅកម្ពុជា

លោកហ្សេហ្វ្រីសេឆ(JEFFRY SACHS)ទីប្រឹក្សាអគ្គលេខាធិការអង្គការសហប្រជាជាតិ បានមកដល់ប្រទេសកម្ពុជាកាលពីល្ងាចថ្ងៃទី៦ សីហា ២០០៥ ដើម្បីនឹងធ្វើការពិភាក្សាជាមួយសមាជិករាជរដ្ឋាភិបាលកម្ពុជាលើការងារគំរោងទិសដៅនៃដំណើរការអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលកម្ពុជាបានចូលរួមជាសមាជិកប្រទេស១០ សាកល្បងក្នុងការជំរុញការអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រ។

នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ លោក ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបានមានប្រសាសន៍ថា: គម្រោងទិសដៅកាត់បន្ថយភាពក្រីក្រប្រចាំសហស្សវត្សរ៍នេះមានចំណុចធំៗ ដូចជាចំណុចទី១ កាត់បន្ថយភាពក្រីក្រឱ្យបាន៥០%ដល់ឆ្នាំ២០១៥។ ប្រជាជនមួយកោដិនាក់រស់នៅបានចំណូលក្រោមមួយដុល្លារ។ ចំណុចទី២គេរកឃើញប្រជាជន១០៣លាននាក់នៅលើពិភពលោកអត់បានចូលរៀន។ ដូច្នេះគេចង់ឱ្យប្រជាជនទាំងនេះបានចូលរៀនគ្រប់ៗគ្នានៅឆ្នាំ២០១៥។ ចំណុចទី៣ ចង់ឱ្យមានភាពស្មើគ្នារវាងបុរស និងស្ត្រី។ ជំរុញឱ្យក្មេងស្រីចូលរៀនស្មើនឹងក្មេងប្រុសៗ។ ចំណុចទី៤ គឺកាត់បន្ថយអត្រាស្លាប់នៃកុមារ។ បច្ចុប្បន្ននេះមានកុមារមួយលាននាក់បានស្លាប់នៅលើពិភពលោកក្រោមអាយុ៥ឆ្នាំ។ ឆ្នាំ២០១៥ ត្រូវកាត់បន្ថយឱ្យបាន២ភាគ៣។ ចំណុចទី៥ កាត់បន្ថយអត្រាស្លាប់នៃស្ត្រីឆ្លងទន្លេ(សម្រាលកូន)ឱ្យបាន៧៥%នៅឆ្នាំ២០១៥។ ចំណុចទី៦ ត្រូវថែរក្សាបរិស្ថានឱ្យបានល្អ។ ត្រូវបង្កើនទឹកស្អាតដល់ប្រជាជនប្រើប្រាស់។ មានប្រជាជនមួយកោដិនៅលើពិភពលោកអត់មានទឹកស្អាតប្រើប្រាស់។ ចំណុចទី៧ ឱ្យដៃគូឯកជនធ្វើការទំនាក់ទំនងជាមួយរាជរដ្ឋាភិបាលបើកទូលាយក្នុងការធ្វើពាណិជ្ជកម្មមានស្ថិរភាពល្អ បង្កើនការងារឱ្យបានច្រើន។

ដោយឡែកកម្ពុជាយើងត្រូវបានបង្កើតគោលដៅមួយចំណុចទៀត គឺធ្វើការកាត់បន្ថយគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ។ ចំណុចចុងក្រោយ គឺកាត់បន្ថយអត្រាជំងឺអេដស៍ឱ្យបានពាក់កណ្តាលសម្រាប់ឆ្នាំ២០១៥។

លោករដ្ឋមន្ត្រីបានឱ្យដឹងទៀតថា ការមកបំពេញទស្សនកិច្ច៣ថ្ងៃនេះ ទីប្រឹក្សាអគ្គលេខាធិការអង្គការសហប្រ-ជាជាតិរូបនេះនឹងទៅមើលភូមិ២ឬ៣នៅស្រុកសំឡូត ខេត្តបាត់ដំបង ដែលនាងអែនចូលី តារាហូលីវូតបានកសាងភូមិទាំងនេះឱ្យមានការរក្សាបរិស្ថានបានល្អ។ បន្ទាប់មកលោក SACHS នឹងជួបសម្តេចក្រុមព្រះជាព្រះប្រធានរដ្ឋសភា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងបណ្តាមន្ត្រីជាន់ខ្ពស់មួយចំនួនទៀតមុននឹងវិលត្រឡប់ទៅវិញនៅថ្ងៃទី៩ សីហា ២០០៥ វេលាម៉ោង១២ថ្ងៃត្រង់ខាងមុខនេះ៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៤៨*
*ថ្ងៃទី ០៩_០៨_០៥*

# EAA បានគំរោងជួយចិញ្ចឹមក្មេងកំព្រា

អង្គការ Enfants d'Asie ASPECA(EAA) មានគំរោងចិញ្ចឹមកុមារកំព្រានៅតាមសហគមន៍ និងស្នើសុំឱ្យរដ្ឋាភិបាលជួយដោះស្រាយទីតាំងដើម្បីសាងសង់អាគារស្នាក់នៅបណ្តោះអាសន្នមួយកន្លែងនៅទីក្រុងភ្នំពេញដើម្បីឱ្យសិស្ស និស្សិតដែលជាកុមារកំព្រានិងទីទ័លក្រនៅតាមខេត្តមកបន្តការសិក្សានៅទីក្រុង។

នៅក្នុងកិច្ចពិភាក្សាគ្នារវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កាលពីថ្ងៃទី៨ សីហា ២០០៥ នៅទីស្នាក់ការក្រសួង លោកស្រី Laurence អនុប្រធានអង្គការ EAA ប្រចាំនៅប្រទេសបារាំងមានប្រសាសន៍ថា អង្គការ EAA មានគំរោងចិញ្ចឹមកុមារកំព្រានៅក្នុងសហគមន៍ ដែលពួកគេកំព្រាម្តាយ ឬឪពុកដោយមិនបញ្ជូលមកក្នុងមណ្ឌលកុមារកំព្រាឡើយ។ លោកស្រីបានបន្តថា EAA ក៏មានគំរោងសាងសង់អាគារស្នាក់នៅបណ្តោះអាសន្នមួយកន្លែងនៅទីក្រុងភ្នំពេញដើម្បីឱ្យសិស្ស និស្សិតកំព្រា និងក្រីក្រមកពីតាមបណ្តាខេត្តបានស្នាក់នៅសិក្សាបន្ត ដែលគំរោងខាងលើនេះ ត្រូវបានឧបត្ថម្ភដោយសប្បុរសជន និងក្រុមហ៊ុននៃប្រទេសបារាំង។ ដូច្នេះហើយទាមទារឱ្យមានការសហការពីរាជរដ្ឋាភិបាលក្នុងការផ្តល់ទីតាំងសមស្របដើម្បីធ្វើការសាងសង់។

លោក អ៊ិត សំហេងថ្លែងនាឱកាសនោះដែរថា ក្រសួងក៏ដូចជារាជ-រដ្ឋាភិបាលសូមស្វាគមន៍ចំពោះគំរោងចិញ្ចឹមកុមារកំព្រានៅតាមសហគមន៍នេះ ហើយនឹងស្នើឱ្យអង្គការលើកជាគំរោងសាងសង់ស្នើរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងផ្តល់កន្លែងសមស្របក្នុងការសាងសង់។ លោកក៏បានជំរាបជូនភ្ញៀវផងដែរថា បច្ចុប្បន្ននៅទូទាំងប្រទេសកម្ពុជាមានកុមារកំព្រាចំនួន១១ម៉ឺននាក់ ដែលបណ្តាលមកពីឪពុកម្តាយរបស់ពួកគេស្លាប់ដោយសារជំងឺអេដស៍ និងគ្រោះថ្នាក់ផ្សេងៗ ដែលពាក់កណ្តាលនៃចំនួននេះ គឺជាកុមារកំព្រាគ្មានឪពុកម្តាយ។

គួររំលឹកផងដែរថា អង្គការ EAA ជាប់បំពេញបេសកកម្មនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩០ រហូតដល់បច្ចុប្បន្ន អង្គការមានមណ្ឌលកុមារកំព្រាចំនួន ៧ ដែលទទួលគ្រប់គ្រងកុមារចំនួន ៤២៦នាក់ ក្នុងនោះស្រី២១៨នាក់ និងមានមណ្ឌលកុមារកំព្រាចំនួន១៦ទៀតនៅទូទាំងប្រទេស ដែលសហការគ្រប់គ្រងជាមួយក្រសួងសង្គមកិច្ចដែលមានកុមារចំនួន៣.១០៦នាក់៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៤៨*
*ថ្ងៃទី ០៩_០៨_០៥*

# បុរសកំរោលមានប្រពន្ធរំលោភក្មេងស្រីអាយុ១៥ឆ្នាំ មានផ្ទៃពោះ៦ខែ បែករឿង

អង្គការលីកាដូប្រចាំខេត្តកំពតបានផ្ញើលិខិតមួយច្បាប់ ចូលមកព្រះរាជអាជ្ញាអមតុលាការខេត្តកំពតឱ្យជួយអន្ត-រាគមន៍ចំពោះពាក្យបណ្តឹងរបស់ឪពុកម្តាយកុមារីរងគ្រោះអាយុ១៥ឆ្នាំ ត្រូវបានបុរសម្នាក់មានប្រពន្ធរួចហើយ ចាប់រំលោភរហូតមានផ្ទៃពោះ។

តាមការបំភ្លឺរបស់ម្តាយកុមារីរងគ្រោះថា កូនស្រីគាត់មិនបានប្រាប់ឱ្យគាត់ដឹងពីរឿងនេះពីមុនមកទេ តែដោយការសង្កេតឃើញពោះរបស់នាងកាន់តែធំទៅៗក៏មានការសង្ស័យ ហើយក៏លួងលោម

សួរការពិតពីនាង នាងក៏ព្រមនិយាយការពិតប្រាប់ថា កាលពីខែមករា ២០០៥ នៅម៉ោងប្រហែល៩យប់ ពេលដែលនាងមើលទូរទស្សន៍ចប់មួយរឿង នាងបានចុះពីផ្ទះដើរទៅផ្ទះយាយនៅខាងត្បូងផ្ទះនាង ចំងាយប្រមាណ៧០ម៉ែត្រ។ លុះដើរចេញដល់ចំនុចកាច់ជ្រុងដើមត្នោតមួយដើម ស្រាប់តែបុរសម្នាក់ស្ទុះចេញមកចាប់ក្តោបមាត់នាងជាប់ ស្រែកមិនរួច និងគំរាមថា បើហ៊ានស្រែកនឹងសំលាប់ចោល។ ពេលនោះទើបនាងស្គាល់ថា បុរសនោះឈ្មោះ ញ៉ែម ភាព ត្រូវជាបងប្អូននឹងនាងដែរ។ បន្ទាប់មកជននោះក៏អូសនាងទៅវាលស្រែចំងាយប្រហែលជា២០ម៉ែត្រពីដើមត្នោត រួចក៏រុញនាងផ្តួលទៅលើដី ចាប់ហែកអាវយកក្រណាត់មកចងមាត់នាងជាប់ធ្វើឱ្យនាងស្រែកមិនរួច ហើយចាប់រំលោភសេពសន្ថវៈលើរូបនាងទាំងកំរោល។

បន្ទាប់ពីរំលោភបានសំរេចហើយ ជននេះបានគំរាមនាងទៀតថាបើហ៊ាននិយាយរឿងនេះប្រាប់ម្តាយឪពុកឬអ្នកណាផ្សេង គេនឹងសំលាប់ចោល។ ចាប់តាំងពីពេលនោះមក នាងមិនហ៊ានប្រាប់អ្នកណាទេ ព្រោះខ្លាចជនល្មើសសំលាប់ ម្យ៉ាងទៀតខ្លាចឮដល់មិត្តភក្តិនិងអ្នកភូមិធ្វើឱ្យនាងខ្មាស់គេ ទើបនាងលាក់បាំងរហូត សូម្បីតែពោះនាងកាន់តែធំនោះក៏នាងមិនដឹងថា ខ្លួននាងមានផ្ទៃពោះផង។

ឪពុកម្តាយកុមារីរងគ្រោះក្រោយពីដឹងរឿងពិតហើយ ក៏បាននាំកូនស្រីទៅផ្ទះជនល្មើសដើម្បីនិយាយគ្នា ដោយមានមេភូមិចូលរួមផងដែរ។ ពេលនោះម្តាយជនល្មើសបានសុំអង្វរធ្វើការដោះស្រាយត្រឹមភូមិបានហើយ ព្រោះជាបងប្អូនសាច់ញាតិនឹងគ្នាកុំឱ្យខ្មាស់គេ។

ឪពុកជនរងគ្រោះបានសុំទារសំណងចំនួន៤លានរៀល តែជនល្មើសព្រមព្រៀងថា បង់ឱ្យតែ២លានរៀលទេ។ បន្ទាប់មកនៅថ្ងៃប្រគល់លុយ ជនល្មើសបែរជាបដិសេធមិនបង់លុយឱ្យទៅវិញ ហើយដេញភាគីរងគ្រោះឱ្យទៅប្តឹង។ សព្វថ្ងៃនេះ តាមការបញ្ជាក់ពីពេទ្យស្រុកបានឱ្យដឹងថា នាងមានផ្ទៃពោះ៦ខែ ហើយបន្ទាប់ពីការចាប់រំលោភ ហើយអាចនឹងសំរាលនៅថ្ងៃទី២ តុលា ២០០៥ ខាងមុខនេះ។

ទាក់ទិននឹងរឿងក្មេងស្រីមានផ្ទៃពោះនេះ លោកស្រី ង៉ែត សូរ្យសែង អ្នកសំរបសំរួលអង្គការលីកាដូប្រចាំខេត្តកំពត មានប្រសាសន៍ថា គួរឱ្យសោកស្តាយដែរ ដោយសារតែនាងមានផ្ទៃពោះ ឪពុកម្តាយមិនដឹង ណាមួយទៀតអាជ្ញាធរមានសមត្ថកិច្ចលាក់បាំងក្នុងសាច់រឿងនេះទុកឱ្យជនល្មើសរួចខ្លួន៕

*ដកស្រង់ចេញពី កោះសន្តិភាព លេខ៥៥០២*
*ថ្ងៃទី១១_០៨_០៥*

# អ៊ំប្រុសរំលោភក្មួយស្រីបង្កើតតុលាការសំរេចដាក់គុក១២ឆ្នាំ

តុលាការខេត្តបន្ទាយមានជ័យក្នុងសវនាការកាលពីល្ងាចថ្ងៃទី២ សីហា បានសំរេចដាក់គុកបុរសម្នាក់ដែលរំលោភក្មួយស្រីបង្កើតរបស់ខ្លួនឱ្យជាប់គុក១២ឆ្នាំ និងសងជំងឺចិត្តចំនួន៤លានរៀល។

គួររំលឹកថា ជនល្មើសនេះត្រូវប៉ូលីសចាប់ខ្លួនបន្ទាប់ពីប្រព្រឹត្តអំពើចាប់រំលោភផ្លូវភេទលើក្មួយស្រី និងមានបណ្តឹងពីគ្រួសារក្មេងស្រីរងគ្រោះ។ ហេតុការណ៍កើតឡើងនៅវេលាម៉ោង១០ និង១០នាទីយប់ថ្ងៃទី១៦ មីនា ២០០៥ នៅលើផ្ទះកុមារីរងគ្រោះ ស្ថិតនៅឃុំសំរោង នៅពេលឪពុកម្តាយក្មេងស្រីពុំនៅផ្ទះ។ ជនល្មើសយកលេសឡើងទៅលើផ្ទះកុមារីរងគ្រោះថា ទៅរាវរកអំពូលកែវឆ្លុះសត្វ រួចក៏វាទៅលើក្មួយស្រីដែលកំពុងតែដេកលក់ ហើយក៏ចាប់សង្កត់យកភួយចុកមាត់ និងសំរាតសំលៀកបំពាក់រំលោភបានសំរេច។

ក្នុងសវនាការ ក្មេងស្រីរងគ្រោះ វ៉.ស.វអាយុ១៤ឆ្នាំបំភ្លឺថា នៅពេលនោះយប់ងងឹតមើលពុំស្គាល់ថាជានរណាទេ តែអ៊ំប្រុសបាននិយាយសំឡុតគំរាមកុំឱ្យនាងនិយាយរឿងអាស្រូវនេះប្រាប់គេឯងទើបនាងស្គាល់ថាជាអ៊ំប្រុសរបស់នាង។

អង្គជំនុំជំរះបានសំរេចដាក់គុកជនល្មើសចំនួន១២ឆ្នាំ និងសងជំងឺចិត្ត៤លានរៀល បន្ទាប់ពីជនល្មើសសារភាពការពិត៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៤៥*
*ថ្ងៃទី០៥_០៨_០៥*

# ផឹកស្រាស្រវឹងដេកមិនលក់លួចចូលក្នុងបន្ទប់កូនក្រមុំគេបំណងរំលោភ តែមិនបានសំរេច

យុវជនម្នាក់បានផឹកស្រាសស្រវឹងដាបដេកមិនលក់លបចូលទៅក្នុងបន្ទប់កូនក្រមុំគេបំណងរំលោភសេពសន្ថវៈតែនាងដឹងខ្លួនទាន់ស្រែកឱ្យម្តាយជួយ។ ហេតុការណ៍នេះកើតឡើងនៅយប់ថ្ងៃទី៧ សីហា ២០០៥ វេលាម៉ោង ២ រំលងអាធ្រាត្រក្នុងភូមិកំណប់ ឃុំជើងរាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ។

ប៉ូលីសបានឱ្យដឹងថា យុវជននោះឈ្មោះ អឿន អាង ភេទប្រុស អាយុ២៤ឆ្នាំ រស់នៅភូមិ_ឃុំកើតហេតុ។ ចំណែកឯកុមារីដែលយុវជននោះបំរុងនឹងចាប់រំលោភ ឈ្មោះព.ច អាយុ១៤ឆ្នាំ នៅភូមិ_ឃុំជាមួយគ្នា។

ប៉ូលីសបន្តថា ក្រោយពេលបែកការណ៍ជនល្មើសបានរត់គេចខ្លួនបាត់ទៅ លុះដល់ព្រឹកឡើង សមត្ថកិច្ចមូលដ្ឋានបានធ្វើការស្រាវជ្រាវ និងឃាត់ខ្លួនជនជាប់ចោទបញ្ជូនមកកាន់ស្នងការដ្ឋានខេត្តកំពង់ស្ពឺតែម្តង។

យោងតាមរបាយការណ៍របស់ប៉ូលីសព្រហ្មទណ្ឌកំរិតធ្ងន់ស្រុកឧត្តុង្គ និងពាក្យបណ្តឹងរបស់ម្តាយកុមារីរងគ្រោះបញ្ជាក់ថា ជនល្មើសឈ្មោះអឿនអាងបានចាប់រំលោភសេពសន្ថវៈលើកូនគាត់ឈ្មោះព.ច បានសំរេចដល់ទីជំរៅ ប៉ុន្តែគ្រូពេទ្យបានអះអាងថា វាមិនបានសំរេចទេ ព្រោះគ្មានស្នាមដាច់រលាត់អ្វីទាំងអស់។

ជនជាប់ចោទបានសារភាពថាខ្លួនពិតជាបានលបចូលទៅក្នុងបន្ទប់កូនក្រមុំគេមែន តែមិនបានរំលោភទេ គឺគ្រាន់តែយកដៃបបោសអង្អែលក្បាលនិងស្មាតែប៉ុណ្ណោះ។

ជនល្មើសបន្តទៀតថា មុនពេលកើតហេតុខ្លួនបានទិញស្រាផឹកអស់ជាច្រើនលីត្រ ហើយដេកមិនលក់ក៏ដើរចូលទៅក្នុងផ្ទះរបស់នាង បំណងទៅបន្លែងលេងព្រោះរូបគេបានលួចស្រលាញ់នាងតាំងពីយូរមកហើយ។

បច្ចុប្បន្នសមត្ថកិច្ចកំពុងសួរចំលើយបន្ថែម ដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការធ្វើការចោទប្រកាន់តាមផ្លូវច្បាប់៕

*ដកស្រង់ចេញពី កម្ពុជាថ្មី លេខ៨០៥*
*ថ្ងៃទី០៩_០៨_០៥*

# ឃុំខ្លួនមន្ត្រីយោធាត្រៃទ័ពម្នាក់ដែលចាប់នារីរំលោភតែពុំបានសំរេច

មន្ត្រីយោធាត្រៃទ័ពម្នាក់ ដែលតណ្ហាឡើងដល់កពុំអាចទ្រាំបានទៅចាប់និងវាយដំលើនារីម្នាក់ដែលរស់នៅអង្គការមិត្តសំលាញ់ ក្នុងបំណងចាប់រំលោភ តែពុំបានសំរេច ត្រូវបានតុលាការសំរេចឃុំខ្លួនបណ្តោះអាសន្នពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ។

មន្ត្រីតុលាការបានអះអាងថានារីរងគ្រោះបានរៀបរាប់ថា កាលពីថ្ងៃទី៣១ កក្កដា ២០០៥ខ្លួននាង និងមិត្តភក្តិស្រីម្នាក់ទៀតបានទៅដើរលេងជាមួយបុរស៤នាក់ ដែលមានបុរសម្នាក់ជាសង្សាររបស់មិត្តស្រីរបស់នាង។ ក្នុងការដើរកំសាន្ត បុរសទាំងនោះបាននាំពួកនាងចូលហូបចុក និងច្រៀងខារ៉ាអូខេ រហូតដល់ពាក់កណ្តាលយប់ នាងមិនហ៊ានទៅសំរាកនៅអង្គការវិញ ក៏ព្រមទៅដេកនៅផ្ទះសំណាក់យីហោ៧៩៩ ក្នុងសង្កាត់ផ្សារថ្មីទី២ ដោយបែងចែកជា២បន្ទប់ គឺមិត្តស្រីរបស់នាង និងសង្សារដេកបន្ទប់មួយ ចំណែកនាង និងបុរស៣នាក់ទៀតដេកនៅបន្ទប់មួយទៀត។ ពេលនោះបុរសជាប់ចោទបានចាប់នាងនៅក្នុងបន្ទប់គោលបំណងរំលោភសេពសន្ថវៈលើរូបនាង នាងក៏បានស្រែកយ៉ាងខ្លាំង ហើយជនល្មើសបានវាយតប់មកលើរូបនាង និងចាប់សម្រាតខោនាងតែម្តង។ ដោយឮសម្រែករបស់នាង មិត្តភក្តិនាងក៏ស្ទុះចេញមកធ្វើអន្តរាគមន៍ទើបព្រាននារីនោះសុខចិត្តដោះលែងនាងវិញ។

មន្ត្រីតុលាការបញ្ជាក់ថា តាមខ្លឹមសារនៃពាក្យបណ្តឹងបានបង្ហាញថា បុរសរូបនេះមានបំណងរួមសិចប្លូកព្រោះក្នុងបន្ទប់នេះមានបុរសដល់ទៅ៣នាក់ឯណោះ។ ប៉ុន្តែដោយសារបុរស២នាក់ទៀតមិនទាន់បានធ្វើសកម្មភាពអ្វី តុលាការពុំអាចធ្វើការចោទប្រកាន់បានទេ។ ចំណែកឯបុរសនោះក្រោយពីបានធ្វើការសាកសួររួចហើយ លោក អ៊ុក សាវុធ ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញបានធ្វើការចោទប្រកាន់ពីបទប៉ុនប៉ង

*តទៅទំព័រទី៥*

*តមកពីទំព័រទី៤*

រំលោភសេពសន្ថវៈ រួចបញ្ជូនសំនុំរឿងនេះទៅឱ្យលោក យ៉ា សុខន ចៅក្រមស៊ើបអង្កេតចាត់ការបន្តតាមនីតិវិធី។ក្នុងនោះចៅក្រមបានសំរេចឃុំខ្លួនបុរសរូបនេះដាក់ពន្ធនាគារជាបណ្តោះអាសន្ន៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៤៥*
*ថ្ងៃទី០៥_០៨_០៥*

---

# សម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែនគាំទ្រក្រសួងកិច្ចការនារីប្រឆាំងការផ្សាយរូបអាសអាភាស

លោកស្រី អ៊ឹង កន្ថាផាវី បានធ្វើការថ្លែងអំណរគុណដល់សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន ដែលបានដាក់បញ្ជាភ្លាមៗទាន់ពេលវេលា ឱ្យមានការចុះបង្ក្រាបអំពើល្មើសយករូបអាក្រាតរបស់នារីខ្មែរធ្វើអាជីវកម្មរកប្រាក់តាមប្រព័ន្ធទូរស័ព្ទដៃនាពេលថ្មីៗនេះ ដោយបានចាត់ទុកថាអំពើនោះបាននាំឱ្យអាប់ឱនកិត្តិយសសេចក្តីថ្លៃថ្នូរជាតិខ្មែរទាំងមូល និងធ្វើឱ្យនារីខ្មែរទូទៅខ្មាស់អៀន និងឈឺចាប់។ បើទោះបីជាមានស្ត្រីខ្លះស្ម័គ្រចិត្តធ្វើដោយហេតុផលក្រីក្រក៏ដោយ ក៏ជាការប្រាសចាកប្រពៃណីទំនៀមទំលាប់ខ្មែរយ៉ាងធ្ងន់ធ្ងរដែរ។

លោកស្រីបានថ្លែងអំណរគុណបែបនេះកាលពីថ្ងៃទី៤ សីហា ក្នុងវេទិកាស្ត្រីមួយដែលបានរៀបចំឡើងនៅក្រសួងកិច្ចការនារី ដើម្បីពិភាក្សាបញ្ហាផ្សព្វផ្សាយរូបអាសអាភាសរបស់នារីខ្មែរតាមរយៈប្រព័ន្ធអេឡិចត្រូនិកកន្លងមក។ វេទិកានេះរៀបចំដោយក្រសួងកិច្ចការនារី និងមានស្ត្រីជាថ្នាក់ដឹកនាំ អ្នកបច្ចេកទេសមកពីបណ្តាស្ថាប័ននានា និងអង្គការក្រៅរដ្ឋាភិបាលជាច្រើនទៀតចូលរួម។

នៅក្នុងវេទិកានោះដែរ ក៏មានលើកឡើងពីលទ្ធផលនៃកិច្ចប្រជុំអន្តរក្រសួងដែលធ្វើឡើងនៅទីស្តីការគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី២៨ កក្កដា កន្លងមក។ ខ្លឹមសារនៃកិច្ចប្រជុំនោះមាន៦ចំណុចរួមមាន ១. សុំសេចក្តីសំរេចពីរាជរដ្ឋាភិបាលដើម្បីបិទ Block IPក្នុង Internet ដែល Block នេះជាអ្នកបញ្ជូនរូបអាសអាភាស រួមមានទាំង Wesite Sex , Webcam, និង Voice Chate ជាដើម។ ២. រៀបចំគណៈកម្មាធិការប្រតិបត្តិយុទ្ធនាការត្រួតពិនិត្យការផ្សព្វផ្សាយរូបភាពអាសអាភាសគ្រប់វិធី ដោយលើកជាផែនការសកម្មភាពភ្ជាប់ជាមួយវិធានការផ្សេងៗ និងស្នើសុំឱ្យមានថវិកាសំរាប់ទ្រទ្រង់សកម្មភាពអប់រំ អង្កេតតាមដានត្រួតពិនិត្យ និងបង្ក្រាបឱ្យមានប្រសិទ្ធិភាព។ ៣. សុំក្រសួងយុត្តិធម៌ពិនិត្យលើសេចក្តីព្រាងច្បាប់ថ្មី ស្តីពីការបង្ក្រាបការជួញដូរមនុស្សដើម្បីបំពេញនូវចន្លោះខ្វះខាត និងជំរុញឱ្យមានការអនុម័តឱ្យបានឆាប់រហ័ស។ ៤. រៀបចំសារាចរណែនាំរបស់រាជរដ្ឋាភិបាល ដើម្បីជួយសំរួលដល់ការអនុវត្តន៍ទប់ស្កាត់ និងបង្ក្រាបក្នុងដំណាក់កាលរង់ចាំការអនុម័តច្បាប់។ ៥. ក្រសួងនីមួយៗត្រូវមានវិធានការណែនាំការអប់រំដល់មន្ត្រីរាជការកុំឱ្យយករូបភាពអាសអាភាសមកមើល ឬផ្សព្វផ្សាយ។ ៦. រៀបចំយុទ្ធនាការអប់រំយុវវ័យអប់រំសង្គម ដោយសហការជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

វេទិកាពិភាក្សានេះបានឯកភាពយល់ព្រមគាំទ្រអំពីខ្លឹមសារទាំង៦ចំណុចរបស់កិច្ចប្រជុំអន្តរក្រសួងដែលធ្វើឡើងនៅទីស្តីការគណៈរដ្ឋមន្ត្រី។

លោកស្រី យីន ផាន្នី នាយិកាប្រតិបត្តិមូលនិធិសង្គ្រោះកុមារអាស៊ីអាគ្នេយ៍បានឡើងថ្លែងមតិទាក់ទិននឹងបញ្ហានេះថា ដើម្បីលុបបំបាត់បញ្ហាអវិជ្ជមានកុំឱ្យកើតមានតទៅទៀតនោះ ទាល់តែកំលាំងសង្គមទាំងមូល ហើយបណ្តាញព័ត៌មានដូចជាទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន ក៏ត្រូវតែចូលរួមដែរក្នុងការរួមចំណែកមិនផ្សព្វផ្សាយរូបភាពបែបអាសអាភាស។ ជាមួយគ្នានេះទៀតស្ថាប័នអ្នកអនុវត្តច្បាប់ក៏ត្រូវតែរួមគ្នាក្នុងការទប់ស្កាត់ផងដែរ។ លោកស្រីបន្តថាត្រូវតែមានការប្រឆាំងក្រុមជនខិលខូចទាំងនេះគឺការផាកពិន័យឱ្យធ្ងន់ធ្ងររួមជាមួយនឹងការនាំខ្លួនឡើងតុលាការ។

នៅក្នុងលិខិតផ្លូវការរបស់ក្រសួងកិច្ចការនារីដែលបានដាក់ជូនសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានកត់សំគាល់ថា នេះជាភាពប្រកាសអាសន្នមួយ ព្រោះបើពុំមានវិធានការ និងបង្ក្រាបទាន់ពេលវេលាទេ នឹងមាននារីរងគ្រោះកាន់តែច្រើនទៀត ដែលធ្វើឱ្យកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់វប្បធម៌ និងប្រពៃណីជាតិនឹងត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ ដើម្បីថែរក្សាបាននូវកិត្តិយសសេចក្តីថ្លៃថ្នូរវប្បធម៌ និងប្រពៃណីជាតិ ក្រសួងកិច្ចការនារី សុំស្នើឡើងនូវអនុ-

សាសន៍មួយចំនួនដូចខាងក្រោម៖

១. សូមរាជរដ្ឋាភិបាលចាត់វិធានការជាបន្ទាន់ដើម្បីស្រាវជ្រាវបង្ក្រាប និងផ្តន្ទាទោសក្រុមជនខិលខូច និងក្រុមហ៊ុនដែលបានប្រព្រឹត្តអំពើអនាចារនេះ និងចាត់វិធានការពង្រឹងការត្រួតពិនិត្យ និងគ្រប់គ្រងប្រព័ន្ធទូរស័ព្ទ និងអ៊ីនធឺណេតឱ្យបានតឹងរ៉ឹង។

២. សូមមេត្តាបន្តពង្រឹងវិធានការបិទកន្លែងបញ្ចាំងវីដេអូអាសអាភាសនៅគ្រប់ខេត្ត-ក្រុងទូទាំងប្រទេស និងបិទការនាំចូលកាសែត និងរូបភាពអាសអាភាសឱ្យបានតឹងតែង ព្រោះនេះជាមូលហេតុនៃអំពើរំលោភសេពសន្ថវៈ និងអំពើអនាចារដទៃទៀត។

៣. ចំពោះប្រព័ន្ធទូរស័ព្ទទំនើបដែលមានរូបភាពអាសអាភាសមិនគួរត្រូវបានលើកទឹកចិត្តឱ្យនាំចូលឡើយ ព្រោះវាជាបច្ច័យអាក្រក់ក្នុងដំណាក់កាលដែលប្រជាជនយើងពុំមានសមត្ថភាពចំណេះដឹងគ្រប់គ្រាន់ ក្នុងការពិចារណា ឬចេះការពារខ្លួនពីអំពើកេងប្រវ័ញ្ចតាមគ្រប់រូបភាពដូចបច្ចុប្បន្ននេះ៕

*ដកស្រង់ចេញពី កោះសន្តិភាព លេខ៥៤៧*
*ថ្ងៃទី០៥-០៨-០៥*

# កុមាររងគ្រោះដោយសារជំងឺអេដស៍រកឃើញជំរកមួយនៅវត្តអូពត

ស្រុកទន្លេបាទី ខេត្តតាកែវ- ទោះបីជាកុមារី គីម សៀក មិនដែលភ្លេចទីកន្លែងដែលនាងត្រូវបានគេនិយាយចំអក និងត្រូវបានចាកចេញដោយក្មេងៗដែលមានសុខភាពល្អជាងនៅក្នុងភូមិរបស់នាងក្តី ក៏នាងមិនចាំពីកន្លែងដែលនាងធ្លាប់តែហៅថាផ្ទះទេ។

កុមារី គីម សៀក អាយុ៥ឆ្នាំ ជាក្មេងដែលមានអាយុតិចជាងគេក្នុងចំណោមក្មេងជាច្រើនទៀត។ នាងបញ្ចេញនូវស្នាមញញឹម ប៉ុន្តែទឹកមុខរបស់នាងបង្ហាញនូវភាពស្មោះត្រង់ណាស់ ស្របជាមួយនឹងគ្រាប់ភ្នែកពណ៌ខ្មៅទាំងគូរបស់នាងសំឡឹងមើលទាំងទឹកមុខមាំដែលបញ្ជាក់ពីនរណាម្នាក់ធ្លាប់ជីវិតលំបាកវេទនាដែលបានចាកចេញផុតពីនាង។ ម្តាយឪពុកនាងទាំងពីរនាក់បានស្លាប់ដោយសារជំងឺអេដស៍ ហើយសព្វថ្ងៃនាងត្រូវបានឆ្លងជំងឺនេះដែរ។

តាមការប៉ាន់ប្រមាណរបស់អង្គការសុខភាពពិភពលោក រួមជាមួយនឹងកម្មវិធីអង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍បង្ហាញថា កុមារចន្លោះពី៧៣០០នាក់ ទៅ ១៤០០០នាក់ ត្រូវបានឆ្លងជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជា។

លោក ធា ផល្លា ជាអគ្គលេខាធិការនៃអាជ្ញាធរជាតិជំងឺអេដស៍បានប្រាប់ឱ្យដឹងថា ២ទៅ៣ឆ្នាំកន្លងទៅនេះ អ្នករកស៊ីផ្លូវភេទមានអត្រានៃការឆ្លងជំងឺអេដស៍កើតខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែករណីដែលត្រូវបានកត់ត្រាទុកលើកទី១របស់កម្ពុជាអស់រយៈពេល១៤ឆ្នាំកន្លងទៅនេះបង្ហាញថា ការចំលងជំងឺនៅពេលនេះសំខាន់ គឺឆ្លងពីប្តីទៅប្រពន្ធ និងកូនរបស់គេ។

លោកបន្តថា តាមការវាយតំលៃរបស់រដ្ឋាភិបាល បច្ចុប្បន្ននេះមានកុមារកំព្រាដែលផ្ទុកជំងឺអេដស៍ចំនួន ៧៧០០០នាក់នៅក្នុងប្រទេសកម្ពុជា ដូចជាបញ្ហារបស់កុមារីគីម សៀកបានក្លាយជារឿងអកុសល្យធម្មតាទៅហើយ។ អង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែងបង្កើតបណ្តាញសុវត្ថិភាពដើម្បីប្រមូលកុមារដែលឆ្លងជំងឺអេដស៍វ័យក្មេងៗ និងថ្មីៗនៅក្នុងប្រទេស។

ទោះបីជាបញ្ហារបស់កុមារី គីម សៀកជាបញ្ហាប្រកបដោយទុក្ខភ័យក្តី ប៉ុន្តែនាងជាកុមារីដែលមានសំណាងម្នាក់ ក្នុងចំណោមកុមារដែលមានសំណាងទាំងឡាយ។ បន្ទាប់ពីឪពុកម្តាយត្រូវបានស្លាប់ដោយសារជំងឺ នាងនៅមានជីដូនដែលនៅថែទាំនាងនៅក្នុងភូមិរបស់នាង។

លោក សាន វ៉ាន់ឌីន ជាអ្នកផ្តួចផ្តើមបង្កើត និងជាអ្នកចាត់ការរួមក្នុងភូមិបាននិយាយថា ប៉ុន្តែដោយសារការរើសអើងធ្វើឱ្យជីដូនរបស់កុមារីមិនអាចអត់ទ្រាំបានក៏នាំនាងទៅនៅវត្តអូពត នៅក្នុងភូមិស្រមោចហែរ ដែលជាកន្លែងសំរាប់ឱ្យកុមារកើតជំងឺអេដស៍ និងយុវវ័យដែលឆ្លងជំងឺអេដស៍ដែលមិនអាចរស់នៅដោយខ្លួនឯងបាន ស្នាក់នៅ។

កុមារីគីម សៀក កំពុងឈរនៅខាងក្រៅកន្លែងដែលនាងរៀនពេលព្រឹកជាមួយក្មេងកំព្រា១៨នាក់ផ្សេងទៀត និងកុមារដែលឆ្លងជំងឺ និយាយថា «នៅពេលដែលខ្ញុំរស់នៅជាមួយជីដូន ខ្ញុំគ្មានមិត្តភក្តិទេ តែឥឡូវខ្ញុំមានមិត្តភក្តិហើយ ខ្ញុំពិតជាសប្បាយចិត្តណាស់ »។

លោកMathysse ជនជាតិអាមេរិក

និយាយថាវត្តអូ្វពតគឺជាអង្គការមួយដែលផ្តល់នូវថ្នាំ និងការថែទាំសុខភាពដល់ប្រជាពលរដ្ឋក្រីក្រ និងជនរងគ្រោះដោយសារជំងឺអេដស៍នៅខេត្តតាកែវ។ អង្គការនេះត្រូវបានចាត់ចែង និងផ្តល់ថវិការដោយលោក សាន វ៉ាន់ឌីនជនជាតិកម្ពុជា និងខ្លួនលោកផ្ទាល់៕

*បកប្រែសង្ខេបក្រៅផ្លូវការពីកាសែតឌីខេមបូឌាដេលី*
*ថ្ងៃទី០៦_០៧ ខែសីហា ឆ្នាំ២០០៥*

# តុលាការផ្តន្ទាទោសអ្នករំលោភក្មេងស្រីម្នាក់នៅស្រុកស្ទឹងត្រង់

តុលាការខេត្តកំពង់ចាមបានសំរេចផ្តន្ទាទោសយុវជនដែលបានចាប់រំលោភសេពសន្ថវៈលើកុមារីម្នាក់នៅស្រុកស្ទឹងត្រង់តាំងពីឆ្នាំ២០០១ ឱ្យជាប់ទោសត្រឹមតែឱ្យនៅក្រៅឃុំប៉ុណ្ណោះកាលពីថ្ងៃទី២សីហាកន្លងទៅនេះ។

យោងតាមពាក្យបណ្តឹងរបស់លោកឈីន ភារិទ្ធ ឪពុកកុមារីរងគ្រោះឈ្មោះ ឆ.ដ.ណ អាយុ១១ឆ្នាំ បានឱ្យដឹងថា កាលពីថ្ងៃទី២៨ តុលា ២០០១ ឈ្មោះឆាយ ដារីត ភេទប្រុស អាយុ១៨ឆ្នាំ មានទីលំនៅជាប់ផ្ទះគាត់ បានលួចចូលក្នុងបន្ទប់ក្រោមផ្ទះចាប់ឆ.ដ.ណដែលកំពុងនៅបន្ទប់ចង្ក្រានបាយរំលោភយ៉ាងសាហាវព្រៃផ្សៃបំផុត។

លោក ឈីន ភារិទ្ធបញ្ជាក់ថាលោកបានយកកូនស្រីទៅពិនិត្យនៅមន្ទីរពេទ្យខេត្តកំពង់ចាម កាលពីថ្ងៃទី៣១ តុលា ២០០១ ហើយគ្រូពេទ្យប្រាប់ថាសន្ទះព្រហ្មចារីមានស្នាមដាច់ថ្មីៗ និងមានឈាមស្រស់។

នៅថ្ងៃទី៦ កុម្ភៈ ២០០២លោកស៊ុម គុជ ចៅក្រមស៊ើបអង្កេតបានចេញដីកាចាប់ខ្លួនឆាយ ដារីត ហើយឃុំខ្លួនបានរយៈពេល១៦ថ្ងៃប៉ុណ្ណោះ លោកក៏បានចេញដីកាបង្គាប់ឱ្យដោះលែងវិញ ព្រោះជនល្មើសមានអាយុទើបតែ១២ឆ្នាំ។

ជុំវិញការដោះលែងជនល្មើសនេះ ភាគីជនរងគ្រោះបានប្តឹងទៅឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍ ក៏បានសំរេចដូចតុលាការខេត្តទៀត ក្រោយមកក៏ឡើងដល់តុលាការកំពូលបានបង្គាប់មកតុលាការខេត្តកំពង់ចាមចាប់ខ្លួនជនល្មើសមកវិញ។

នៅថ្ងៃទី២៥ មិថុនា ២០០៥ ឈ្មោះឆាយ ដារីត ត្រូវបានចាប់ខ្លួនជាលើកទី២ ហើយតុលាការខេត្តកំពង់ចាមបានលើកយករឿងក្តីនេះមកបើកសវនាការនៅព្រឹកថ្ងៃទី២ សីហា ២០០៥ ដែលមាន លោក ខិត សិទ្ធី ជាចៅក្រមជំនុំជម្រះ លោក ម៉ក់ ភាង ជាតំណាងអយ្យការ លោកស្រី ហាក់ ជាក្រឡាបញ្ជី និងមានមេធាវីការពារទាំងដើមចោទ និងចុងចោទ។

ជាចុងក្រោយតុលាការបានប្រកាសសាលក្រមឱ្យឈ្មោះ ឆាយ ដារីត ភេទប្រុស អាយុ១៦ឆ្នាំ (គិតឆ្នាំកំណើត ១៩៨៩) ដាក់ពន្ធនាគារ២ឆ្នាំ តែទោសនេះត្រូវព្យួររយៈពេលសាកល្បង៥ឆ្នាំ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ។ សាលក្រមបង្គាប់ទៀតថា ឱ្យដោះលែងឈ្មោះឆាយ ដារីតចាប់ពីពេលនេះតទៅតាមមាត្រា១៥២នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងតាមសំណូមពររបស់ឪពុកជនរងគ្រោះឈ្មោះ ឈីន ភារិទ្ធ។ ហើយសាលក្រមបញ្ជាក់ទៀតថា អាណាព្យាបាលជនជាប់ចោទសងជំងឺចិត្តឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីប្រាំរយដុល្លារអាមេរិកតាមការសំរុះសំរួលរវាងមេធាវីទាំងសងខាង។

មន្ត្រីអង្គការសិទ្ធិមនុស្សដែលឃ្លាំចាំមើលរឿងនេះនិយាយរិះគន់ថា ខាងតុលាការហាក់ដូចជាមានចេតនាចង់ឱ្យជនល្មើសរួចពីទោស ព្រោះថាជននេះប្រព្រឹត្តបទឧក្រិដ្ឋជាក់ស្តែង តុលាការព្យាយាមលើកយកតែឆ្នាំកំណើតរបស់ជនជាប់ចោទត្រឹមតែឆ្នាំ១៩៨៩ ដែលឆ្នាំកំណើតនេះ មិនដឹងជាបានចេញពីប្រភពណា ហើយបែរជាច្រានចោលឆ្នាំកំណើតពិតប្រាកដរបស់ប៉ូលីសមូលដ្ឋានបញ្ជូនមកឱ្យនោះទៅវិញ ហើយមួយចំនុចទៀតនៃសាលក្រមនេះ តុលាការបានរកលេសដើម្បីអំណោយផលសំរាប់ជនល្មើស ដូចជាថាតាមសំណូមពររបស់ឪពុកជនរងគ្រោះសុំឱ្យដោះលែងឆាយ ដារីតជាដើម។

ប្រភពនោះបញ្ជាក់ឱ្យដឹងថា ចំពោះមេធាវីដើមចោទវិញ ហាក់ដូចជាមិនតស៊ូមតិដើម្បីការពារកូនក្តីរបស់ខ្លួននៅចំពោះសវនាការនោះ បែរជាទុកឱកាសឱ្យមេធាវីចុងចោទរកវិធីដោះបន្ទុកឱ្យកូនក្តីរបស់គេយ៉ាងងាយៗបំផុតជាមួយតុលាការ។

អ្នកច្បាប់ម្នាក់បានឱ្យដឹងថា ចំណាត់ការរបស់តុលាការខេត្តកំពង់ចាមដូចជាអយុត្តិធម៌លើជនរងគ្រោះពេកហើយ ព្រោះថាបើតាមច្បាប់ព្រហ្មទណ្ឌអន្តរកាលក្តី ឬច្បាប់ស្តីពីស្ថានទម្ងន់ទោសក្តី តុលាការមិនអាចដោះលែងអនីតិជនដែលអាចប្រព្រឹត្តបទល្មើសឧក្រិដ្ឋបានឡើយ យ៉ាងហោចណាស់គួរផ្តន្ទាទោសត្រឹមពាក់កណ្តាលនៃទោសនីតិជនក្នុងបទល្មើសឧក្រិដ្ឋដូចគ្នា៕

*ដកស្រង់ចេញពី ស្មើកម្ពុជា លេខ៣៧៤៥*
*ថ្ងៃទី០៥_០៨_០៥*

# អំពាវនាវទប់ស្កាត់យុវជនសេពគ្រឿងញៀន

តាម V.O.A: អ្នកតំណាងរាស្ត្រ ៣រូបនៅមណ្ឌលបាត់ដំបង និងបន្ទាយមានជ័យមកពីគណបក្សសម រង្ស៊ី និង ហ៊្វុនស៊ិនប៉ិច គឺលោក អ៊េង ឆៃអ៊ាង លោកស្រី គី លំអង និងលោកគឹម សុភារិទ្ធ បានស្នើសុំឱ្យរដ្ឋាភិបាល និងក្រសួងមហាផ្ទៃជួយធ្វើការអន្តរាគមន៍ទប់ស្កាត់ និងកំចាត់ជាបន្ទាន់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀនដែលកំពុងរីករាលដាលយ៉ាងធ្ងន់ធ្ងរនៅព្រំដែនជាប់ខេត្តទាំង២នោះ ដើម្បីបញ្ចៀសការប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ការអំពាវនាវនេះកើតមានបន្ទាប់ពីមានការជួញដូរ និងប្រើប្រាស់គ្រឿងញៀនកាន់តែច្រើនឡើងក្នុងស្រទាប់យុវវ័យ ជាពិសេសសិស្សដែលគេចវេះពីការរៀនសូត្រឈ្លក់វង្វេងទៅនឹងការសេពគ្រឿងញៀន និងបានប្រព្រឹត្តអំពើអនាធិបតេយ្យជាច្រើនរូបភាពដែលពុំទាន់ឃើញអាជ្ញាធរទប់ស្កាត់ឱ្យបានទាន់ពេលវេលា។ លោកស្រីគី លំអង តំណាងរាស្ត្រនៃមណ្ឌលបាត់ដំបងមកពីគណបក្សហ៊្វុនស៊ិនប៉ិច បានស្នើសុំទៅឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង និងសម្តេចនរោត្តម សិរីវុឌ្ឍឱ្យចាត់វិធានការ ជាក់ស្តែងកំចាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀននេះ ដោយលោកស្រីទទួលបានស្នាមមេដៃប្រជាពលរដ្ឋចំនួន១៤៨៦៣នាក់នៅខេត្តបាត់ដំបង និងបន្ទាយមានជ័យ ស្នើសុំឱ្យថ្នាក់ដឹកនាំជួយអន្តរាគមន៍ជាបន្ទាន់។ លោកស្រីបានបន្ថែមថា គ្រឿងញៀនជាគ្រោះថ្នាក់ដ៏ធំដល់សង្គមជាតិទាំងមូល ព្រោះវាបំផ្លាញដល់យុវជនយុវនារីដែលប្រើប្រាស់វា។

គួរបញ្ជាក់ថា សេចក្តីអំពាវនាវនេះចេញពីការឯកភាពរួមនៃកិច្ចប្រជុំរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនៃមណ្ឌលទាំង២គឺបន្ទាយមានជ័យ និងបាត់ដំបង ដែលរៀបចំឡើងដោយវិទ្យាស្ថានជាតិប្រជាធិបតេយ្យសំរាប់កិច្ចការអន្តរជាតិ អិនឌីអាយ កាលពីពេលថ្មីៗកន្លងមក៕

*ដកស្រង់ចេញពី កោះសន្តិភាព លេខ៥៤៩៧*
*ថ្ងៃទី០៥_០៨_០៥*

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ
NGO Committee on the Rights of the Child

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ(គ.អ.ស.ក)ជាសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលមួយដែលមានអង្គការជាសមាជិកចំនួន៤០។ គ.អ.ស.ក មានតួនាទីធ្វើការលើកកំពស់ការយល់ដឹងអំពីសិទ្ធិកុមារ ធ្វើការងារតស៊ូមតិ និងតាមដានការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។

ដោយយល់ឃើញពីតំរូវការចាំបាច់នៃការប្រមូលផ្តុំ ចងក្រង និងផ្សព្វផ្សាយព័ត៌មាននានាដែលទាក់ទងនឹងកុមារនៅក្នុងប្រទេសកម្ពុជា ទើបគ.អ.ស.ករៀបចំសំរង់ព័ត៌មានប្រចាំសប្តាហ៍នេះដែលជាការដកស្រង់ពត៌មានទាក់ទងនឹងកុមារពីអត្ថបទនៃបណ្តាសារព័ត៌មាននានាដែលវាពុំមែនជាគំនិត ឬទស្សនៈរបស់គ.អ.ស.កទេ។

អាសយដ្ឋានទំនាក់ទំនង: ផ្ទះកុមារ លេខ៨A ផ្លូវ១៣៨ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ២៣ ៨៨២ ៤១២
ទូរសារ : (៨៥៥) ២៣ ៨៨២ ៤១២
អ៊ីមែល : ch.ngocrc@online.com.kh